ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្រ្តីរាជការទាំងអស់មេត្តាជ្រាបថា **ឧបាសិកា ហែម ជា** ដែលត្រូវជាម្តាយ **ឯកឧត្តម អែវ ប៊ុនថុល** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានទទួលមរណភាពនៅថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១០:៥៨នាទី ក្នុងជន្មាយុ ៩០ឆ្នាំ ដោយជរាពាធ។

**ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្រ្តីក្រសួងមុខងារសាធារណៈ នឹងអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃព្រហស្បតិ៍ ទី២៥ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០២:៣០នាទីរសៀល នៅផ្ទះលេខ៧៣ ផ្លូវBT២៥ ភូមិសន្សំកុសល៤ សង្កាត់បឹងទំពុន១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាប ជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

ថ្ងៃ ពុធ ១២ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងមុខងារសាធារណៈ *

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## ឯកឧត្តម អែម ប៊ុនថុល រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ

## និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោកស្តាយជាពន់ពេកដោយបានទទួលដំណឹងថា **ឧបាសិកា ហែម ជា** ដែលត្រូវជាម្តាយបង្កើតរបស់ឯកឧត្តមបានទទួលមរណភាព នៅថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១០:៥៨នាទីព្រឹក ក្នុងជន្មាយុ ៩០ឆ្នាំ ដោយជរាពាធ។

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឧបាសិកា ហែម ជា** ដែលជាម្តាយដ៏ឧត្តម ជាម្តាយក្មេក ជាជីដូនដែលប្រកបដោយសង្គហធម៌ដ៏ល្អប្រពៃ ព្រហ្មវិហារធម៌មិនចេះរីងស្ងួត។

ខ្ញុំសូមសម្តែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធ **ឧបាសិកា ហែម ជា** សូមវិញ្ញាណក្ខន្ធបានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមរដ្ឋលេខាធិការ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុត និងសេចក្តីរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ៕

ថ្ងៃ ពុធ ១២ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ហ៊ុន ម៉ានី

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh